R.U.L.E

ELBBL

English Language Based
Bachelor of Law Program

LAW CLINIC

RULE - English Language Based
Bachelor of Law (ELBBL) Program

**Royal University of Law and Economics**
**English language Based Bachelor of Law Program**

# ការបែងចែកមរតក



# មាតិកា

I.សេចក្តីផ្តើម

II. និយមន័យ

IIII. លក្ខណៈសម្បត្តិនៃអ្នកស្នងមរតក

IV.  អានុភាពនៃបណ្តាំ

V. សន្តតិកម្មតាមបណ្តាំ

១.បណ្តាំដោយលិខិតយថាភូត

២.បណ្តាំដោយលិខិតឯកជន

៣.បណ្តាំដោយលិខិតសម្ងាត់

VI. សន្តតិកម្មតាមច្បាប់

១.សន្តតិជនលំដាប់ទី១

២.សន្តតិជនលំដាប់ទី២

៣.សន្តតិជនលំដាប់ទី៣

៤.សន្តតិជនជានិច្ច ឬអចិន្ត្រៃយ៍

៥. សន្តតិជនជំនួស

VII.សេចក្តីសន្និដ្ឋាន

# I. សេចក្តីផ្តើម

មនុស្សយើងម្នាក់ៗកើតមកហើយ គ្មាននរណាម្នាក់អាចរួចផុតពីសេចក្តីស្លាប់នោះទេ ។ មុននិងក្រោយ គង់តែត្រូវស្លាប់ដូចតែគ្នា គ្រាន់តែមូលហេតុនៃការស្លាប់របស់មនុស្សម្នាក់ៗមានភាពខុសគ្នា ។ ប៉ុន្តែនៅមុនពេលស្លាប់ ទ្រព្យសម្បត្តិដែលខំរកបានតើគួរធ្វើការបែងចែកតាមវិធីណាទើបល្អ ? និងដោយរបៀបណា ? ហើយក្រោយពេល ស្លាប់ តើទ្រព្យសម្បត្តិនោះត្រូវធ្លាក់ទៅលើអ្នកណា ប្រសិនបើម្ចាស់ទ្រព្យមិនបានធ្វើការបែងចែកពេលដែរនៅពេលមានជីវិត ?

នៅក្នុងបរិបទសង្គមយើងសព្វថ្ងៃ ច្បាប់ទទួលស្គាល់ពីទ្រព្យសម្បត្តិដែលបន្សល់ទុកពីដូនតា មកឱ្យកូនចៅជំនាន់ក្រោយ ដែលហៅថា “សន្តតិកម្ម” ។ តើអ្វីទៅហៅថាសន្តតិកម្ម ? តើសន្តតិកម្មមានប៉ុន្មានប្រភេទ  និងប៉ុន្មានទម្រង់ ?  ប្រធានបទមួយនេះ នឹងធ្វើការបកស្រាយនូវចំណុចទាំងអស់នេះ។



# II. និយមន័យ

- និយមន័យ

+សន្តតិកម្ម ឬ ការបែងចែកមរតកគឺជាការផ្ទេរនូវសិទ្ធិ និងករណីកិច្ចរបស់អ្នកទទួលមរណភាពទៅឱ្យអ្នកស្នងមរតកម្នាក់ ឬច្រើននាក់ តាមឆន្ទៈ ឬ តាមច្បាប់។

+សន្តតិជន ឬ អ្នកស្នងមរតក សំដៅលើជនដែលទទួលបន្តនូវសិទ្ធិ និងករណីកិច្ចរបស់អ្នកទទួលមរណភាពតាមរយៈសន្តតិកម្ម។

+មតកជន សំដៅដល់ជនដែលបានស្លាប់ទៅហើយ។

- សន្តតិកម្មត្រូវបានបែងចែកជា២ប្រភេទ គឺ សន្តតិកម្មតាមបណ្តាំ និង សន្តតិកម្មតាមច្បាប់ ។

+សន្តតិកម្មផ្អែកតាមបញ្ញត្តិនៃច្បាប់ ហៅថា សន្តតិកម្មតាមច្បាប់។

ឧទាហរណ៍: លោក ដារា បានទទួលមរណភាពដោយមិនបានបន្សល់ទុកនូវបណ្តាំ ។ ដូច្នេះ ទ្រព្យសម្បត្តិរបស់លោក ដារា ត្រូវបែងចែកតាមច្បាប់ ។

+សន្តតិកម្មផ្អែកតាមឆន្ទៈរបស់មតកជនហៅថា សន្តតិកម្មតាមបណ្តាំ ។

ឧទាហរណ៍: លោក សុខា បានធ្វើបណ្តាំបែងចែកទ្រព្យសម្បត្តិរួចរាល់តាំងពីលោកនៅមានជីវិត។ ដូច្នេះនៅពេលលោកសុខាស្លាប់ទ្រព្យនឹងត្រូវបែងចែកតាមបណ្តាំរបស់លោកសុខា ដែលបានចែងនៅក្នុងលិខិតបណ្តាំ។

# III. លក្ខណៈសម្បត្តិនៃអ្នកស្នងមរតក

+អ្នកស្នងមរតក គឺ ជនដែលអាចទទួលបន្តនូវទ្រព្យសម្បត្តិរបស់ជនដែលបានស្លាប់ តាមរយៈការចាត់ចែងទ្រព្យសម្បត្តិ ។

+អភ័ព្វបុគ្គល គឺ ជនដែលមិនអាចទទួលបន្តនូវទ្រព្យសម្បត្តិរបស់ជនដែលបានបាត់បង់ជីវិត តាមរយៈសន្តតិកម្ម ។ ក៏ប៉ុន្តែ គូភាគីត្រូវបង្ហាញភស្តុតាង និង អះអាងថាអភ័ព្វបុគ្គលនោះបានប្រព្រឹត្តអំពើដែលច្បាប់បានហាមឃាត់ពិតប្រាកដមែន ។



ឧទាហរណ៍ ១៖  ជនដែលក្លែងបន្លំបណ្តាំ, ជនដែលប្រមាថ និង ធ្វើបាបមតកជនយ៉ាងធ្ងន់ធ្ងរ ។ល។

ឧទាហរណ៍ ២៖ សុខជាកូនរបស់ តុលា បានព្យាយាមធ្វើឯកសារ និងគំរាម តុលាឱ្យផ្ទេរកម្មសិទ្ធិលើដី ឬផ្ទះជូនសុខពេលតុលាកំពុងឈឺធ្ងន់នៅមន្ទីរពេទ្យ។

មាត្រា ១១៥០  នៃក្រមរដ្ឋប្បវេណី

# IV. អានុភាពនៃបណ្តាំ

បណ្តាំត្រូវបង្កើតអានុភាពចាប់ពីពេលដែលម្ចាស់បណ្តាំបានទទួលមរណភាព។ នៅក្នុងករណីដែលបណ្តាំភ្ជាប់ជាមួយនឹងល័ក្ខខ័ណ្ឌបង្អង់បណ្តាំនោះត្រូវមានអានុភាពចាប់ពីពេលដែលល័ក្ខខ័ណ្ឌនោះ ត្រូវបានបំពេញ ។

ឧទាហរណ៍៖ នៅក្នុងបណ្តាំបញ្ជាក់ថា “ទទួលបានទ្រព្យសម្បត្តិលុះត្រាតែរៀបការហើយ” ។

# V. ទម្រង់នៃសន្តតិកម្ម



សន្តតិកម្មតាមបណ្តាំ គឺធ្វើឡើងដោយផ្អែកតាមឆន្ទៈរបស់ម្ចាស់បណ្តាំ ដើម្បីសម្តែងឆន្ទៈចុងក្រោយ ដែលសំដៅទៅលើការធ្វើចាត់ចែងទ្រព្យនៅសល់ បន្ទាប់ពីមរណភាពរបស់ខ្លួន ។

តាមច្បាប់កម្ពុជាបច្ចុប្បន្ន សន្តតិកម្មតាមបណ្តាំរួមមាន៖

- បណ្តាំដោយលិខិតយថាភូត
- បណ្តាំដោយលិខិតឯកជន
- បណ្តាំដោយលិខិតសម្ងាត់ ។



មាត្រា ១១៧៣, មាត្រា១១៧៤, មាត្រា១១៧៥ នៃក្រមរដ្ឋប្បវេណី

# ១.បណ្ដាំដោយលិខិតយថាភូត

⭐បណ្ដាំដោយលិខិតយថាភូត គឺជាលិខិតដែលមតកជនត្រូវធ្វើនៅចំពោះមុខសារការី ឱ្យតាមទម្រង់ដូចខាងក្រោម៖

- ម្ចាស់បណ្ដាំត្រូវពន្យល់ពីគោលគំនិតបណ្ដាំចំពោះសារការី
- ត្រូវមានវត្តមានរបស់សាក្សីយ៉ាងតិច២នាក់
- សារការីត្រូវសរសេរអំពីខ្លឹមសារនៃបណ្ដាំជាលាយលក្ខណ៍អក្សរនិងត្រូវអានឱ្យម្ចាស់បណ្ដាំស្ដាប់
- ម្ចាស់បណ្ដាំ សាក្សី និងសារការី ត្រូវចុះហត្ថលេខា លើលិខិតនោះ ។

លិខិតបណ្ដាំដោយយថាភូតនៅពេលអនុវត្តមិនចាំបាច់មានការបញ្ជាក់ពីតុលាការ។



សារការីជាមន្ត្រីសាធារណៈដែលទទួលបាននូវសិទ្ធិអំណាចក្នុងការតាក់តែងលិខិតយថាភូតត្រឹមត្រូវ និងស្របច្បាប់។

មាត្រា ១១៧៣ នៃក្រមរដ្ឋប្បវេណី

# ១.បណ្តាំដោយលិខិតយថាភូត

**ឧទាហរណ៍៖ បុរី ដឹងថាខ្លួនឯងថានៅរស់មិនបានយូរ ហេតុនេះក៏សម្រេចចិត្តទៅធ្វើបណ្តាំមរតកនៅចំពោះមុខសារការី និងនៅចំពោះមុខសាក្សីពីរនាក់។**




មាត្រា ១១៧៣ នៃក្រមរដ្ឋប្បវេណី

# ២.បណ្ដាំដោយលិខិតឯកជន

⭐ បណ្ដាំដោយលិខិតឯកជន គឺជាបណ្ដាំដែលម្ចាស់បណ្ដាំត្រូវសរសេរពាក្យទាំងអស់ដោយផ្ទាល់ដៃ តាមទម្រង់ខាងក្រោម៖

- ម្ចាស់បណ្ដាំត្រូវសរសេរអំពីខ្លឹមសារទាំងមូលនៃបណ្ដាំ ហើយចុះថ្ងៃខែឆ្នាំព្រមទាំងចុះហត្ថលេខាដោយខ្លួនឯង។

ដើម្បីអនុវត្តលិខិតបណ្ដាំដោយលិខិតឯកជន ចាំបាច់មានការបញ្ជាក់ពីតុលាការ។



មាត្រា ១១៧៤, មាត្រា ១១៧៣ នៃក្រមរដ្ឋប្បវេណី

# ៣.បណ្តាំដោយលិខិតសម្ងាត់

⭐បណ្តាំដោយលិខិតសម្ងាត់ គឺជាបណ្តាំមួយប្រភេទដែលមានគោលបំណងរក្សានូវខ្លឹមសារសម្ងាត់ទាំងស្រុង ការពារការលុបចោល ឬការបន្លំដោយអ្នកដទៃ ។ លិខិតបណ្តាំនេះអាចសរសេរដោយម្ចាស់បណ្តាំផ្ទាល់ដៃ ឬប្រើម៉ាស៊ីនដូចជាកំព្យូទ័រ ឬឱ្យគេសរសេរជំនួស (មេធាវីជាអាទិ៍) តាមទម្រង់ខាងក្រោម ៖

- ម្ចាស់បណ្តាំត្រូវចុះហត្ថលេខាក្នុងលិខិត
- ត្រូវដាក់លិខិតនោះ ក្នុងស្រោមសំបុត្របិទជិត
- ត្រូវដាក់នៅចំពោះមុខសារការីម្នាក់ និងសាក្សីពីរនាក់ ដោយថ្លែងការណ៍ថា នេះគឺជាបណ្តាំ
- សារការី ម្ចាស់បណ្តាំ សាក្សី ត្រូវចុះហត្ថលេខាលើលិខិតបិទជិតនោះ ។

**ការអនុវត្តលិខិតបណ្តាំដោយលិខិតសម្ងាត់ចាំបាច់មានការបញ្ជាក់ពីតុលាការ។**

មាត្រា ១១៧៩ នៃក្រមរដ្ឋប្បវេណី

# VI.សន្តតិជន

⭐ជាទូទៅតាមច្បាប់បញ្ញត្តិ សន្តតិជនគឺជាញាតិលោហិតដែលត្រូវកំណត់តាមលំដាប់

- លំដាប់ទី១: កូនរបស់មតកជន
- លំដាប់ទី២: បុព្វញាតិផ្ទាល់
- លំដាប់ទី៣: បងប្អូនបង្កើត

មាត្រា ១១៥៦, មាត្រា ១១៥៩, មាត្រា ១១៦០ នៃក្រមរដ្ឋប្បវេណី

## ១.សន្តតិជនលំដាប់ទី១

សន្តតិជនលំដាប់ទី១ គឺជាកូនរបស់មតកជន ទោះបីជាកូនបង្កើត ឬកូនសុំក្តីត្រូវក្លាយជាសន្តតិជន និងត្រូវទទួលបានចំណែកមត៌កស្មើៗគ្នាតាមច្បាប់កំណត់។






មាត្រា ១១៥៦ នៃក្រមរដ្ឋប្បវេណី

## ២.សន្តតិជនលំដាប់ទី២

សន្តតិជនលំដាប់ទី២ បុព្វញាតិផ្ទាល់មានដូចជា ឪពុកម្តាយ ជីដូនជីតា ជាដើម។ បុព្វញាតិផ្ទាល់អាចក្លាយ ជាសន្តតិជនបាន ក្នុងករណីដែលមតកជន(សុខា) ពុំមានបច្ឆាញាតិផ្ទាល់ដូចជាកូន ឬចៅតែប៉ុណ្ណោះ។ ប្រសិនបើ បុព្វញាតិផ្ទាល់មានច្រើននាក់ត្រូវផ្តល់អទិភាព ចំពោះបុព្វញាតិ ផ្ទាល់ដែលនៅជិតជាមួយមតកជនជាមុន។

ឧទាហរណ៍៖ ឪពុកម្តាយ > ជីដូនជីតា > ជីលួត






មាត្រា ១១៥៩ នៃក្រមរដ្ឋប្បវេណី

## ៣.សន្តតិជនលំដាប់ទី៣

**សន្តតិជនលំដាប់ទី៣ គឺជាបងប្អូនបង្កើតរបស់មតកជន ត្រូវក្លាយជាសន្តតិជនរបស់មតកជន ក្នុងករណីដែលមតកជននោះពុំមានទាំងបច្ឆាញាតិផ្ទាល់ និងទាំងបុព្វញាតិផ្ទាល់តែប៉ុណ្ណោះ ហើយចំណែកមត៌កត្រូវចែកស្មើៗគ្នា។**




មាត្រា ១១៦០ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី

⭐ចំពោះមត៌ករបស់បងប្អូន ដែលមានឪពុក ឬ ម្ដាយតែម្ខាងដូចគ្នាត្រូវមាន១ភាគ២ នៃចំណែកមត៌ករបស់បងប្អូនបង្កើតដែលមាន ឪពុក និង ម្ដាយទាំងសងខាងដូចគ្នា។

ឧទាហរណ៍៖ ប្រសិនបើបងប្អូនសុខាទទួលបាន ១០ ម៉ឺនរៀល នោះប្អូនសុខាដែលជាកូនរបស់ឪពុកចុងសុខានឹងទទួលបាន៥ម៉ឺនរៀល។






មាត្រា ១១៦០ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី

## ៤.សន្តតិជនជានិច្ច ឬអចិន្ត្រៃយ៍

⭐សហព័ទ្ធ មានន័យថាជាប្តី ឬប្រពន្ធរបស់មតកជន

⭐ សហព័ទ្ធ ត្រូវបានចាត់ទុកជាសន្តតិជនជានិច្ច ឬអចិន្ត្រៃយ៍ ទោះបីនៅក្នុងករណីសន្តតិជនលំដាប់ទីប៉ុន្មានក៏ដោយ ក៏សហព័ទ្ធត្រូវក្លាយជាសន្តតិជនជាមួយពួកគេជានិច្ច ហើយត្រូវបានទទួលបានចំណែកមត៌កស្មើៗគ្នា។

ឧទាហរណ៍៖ ក្នុងលំដាប់ទី១






មាត្រា ១១៦១, មាត្រា ១១៦២ នៃក្រមរដ្ឋប្បវេណី

# ៤.សន្តតិជនជានិច្ច ឬអចិន្ត្រៃយ៍ (ត)

**ឧទាហរណ៍៖** ក្នុងលំដាប់ទី២




មាត្រា ១១៦១, មាត្រា ១១៦២ នៃក្រមរដ្ឋប្បវេណី

# ៥.សន្តតិជនជំនួស

⭐ក្នុងករណីដែលកូន ក របស់មតកជន (សុខា) មានកូន ដែលកូននោះត្រូវជាចៅរបស់មតកជន (សុខា) ហើយកូនក របស់មតកជន(សុខា) បានស្លាប់មុនមតកជន(សុខា) នោះអ្នកដែលទទួលមត៌ករបស់មតកជន(សុខា)ជំនួសឱ្យកូនក គឺចៅ។ ករណីបែបនេះគេហៅថា សន្តតិកម្មជំនួស។






មាត្រា ១១៥៧ នៃក្រមរដ្ឋប្បវេណី

# VII. សេចក្ដីសន្និដ្ឋាន

ការបែងចែកទ្រព្យតាមសន្តតិកម្មបានផ្តល់សិទ្ធិដ៏ទូលំទូលាយដល់បុគ្គលគ្រប់រូបក្នុងការបង្ហាញឆន្ទៈក្នុងការកំណត់បុគ្គលណាដែលអាចទទួលបាននូវទ្រព្យរបស់ខ្លួន ទោះបីជាសន្តតិជនទាំងឡាយមានសិទ្ធិក្នុងការ បោះបង់នូវការទទួលនេះនៅពេលសន្តតិកម្មបានចាប់ផ្តើមក៏ដោយ ។

# ឯកសារយោង

១. ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

២. មន្ទីរសារការីភ្នំពេញ លោកស្រី មិន្ទស៊ុំ សូលីដា, “មតកសាសន៍ ៖ សារៈសំខាន់នៃយថាភូតភាព”, ខែ កញ្ញា ឆ្នាំ២០១៦ ។

ឯកសារខាងលើនេះ គឺជាតម្រូវការមួយសម្រាប់ការបញ្ចប់វគ្គជំនាញវិជ្ជាជីវៈច្បាប់ (Professional Legal Skill) នៃកម្មវិធីថ្នាក់បរិញ្ញាបត្រនីតិសាស្រ្តសិក្សាជាភាសាអង់គ្លេស(ELBBL) នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច (RULE) ដែលបានបង្កើតឡើងក្នុងគោលបំណងអប់រំ និងចែករំលែកចំណេះដឹងផ្នែកច្បាប់ប៉ុណ្ណោះ។ ពួកយើងស្វាគមន៍ក្នុងការទទួលនូវមតិសម្រាប់ធ្វើការកែលម្អ។

## ដឹកនាំដោយ៖

កញ្ញា ហ៊ីង វ៉ាន់ដាណែត

កញ្ញា ណៃ សុខម៉េង

---

## រៀបរៀងដោយនិស្សិត៖

១. ស៊ីន ច័ន្ទសុភាព

២. សេង ម៉ាធីណា

៣. គង់ កាណារី

៤. ឃួន សុគន្ធា

## គាំទ្រដោយ ៖